ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

-សំណុំរឿងរដ្ឋប្បវេណីលេខ៖ ១៣៦ ចុះថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ ២០១៨

-សញ្ញាណរឿងក្ដី៖ ប្ដឹងសុំលែងលះប្រពន្ធ

-កាលបរិច្ឆេទបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ថ្ងៃទី ២០ ខែសីហា ឆ្នាំ២០១៨

-សាលក្រមលេខ៖ ០១ (ធ)ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ២០១៨

**នាមនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងខេត្តកណ្ដាល**

ចេញសាលក្រមដែលមានខ្លឹមសារដូចតទៅ៖

-ដើមចោទឈ្មោះ [redacted] សាមឿន ភេទប្រុស អាយុ៤១ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ដោយមានលោក [redacted] និងលោក [redacted] និង លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ។

-ចុងចម្លើយឈ្មោះ [redacted] ថាវី ភេទស្រី អាយុ៣២ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅ [redacted]។

**<u>អង្គហេតុ និងចំណុចទាន</u>**

**១. សាលក្រមដែលទាមទារដោយភាគី៖**

សុំឱតុការចេញសាលក្រមសម្រេច៖

-សុំលែងលះប្រពន្ធឈ្មោះ [redacted] ថាវី ។

-សុំប្រគល់កូនឈ្មោះ [redacted] សីគាវ៉ា ភេទស្រី កើតថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១១ ទៅអោយប្រពន្ធគ្រប់គ្រងចិញ្ចឹមបីបាច់ថែរក្សា។

-សុំផ្ដល់អាហារកិច្ចចិញ្ចឹមកូនតាមលទ្ធភាព ។

**២. ការពន្យល់គ្រួសៗអំពីរឿងក្ដី**

កាលពីឆ្នាំ២០០៨ដើមចោទឈ្មោះ [redacted] សាមឿន បានរៀបការជាមួយចុងចម្លើយឈ្មោះ [redacted] ថាវី និង

បានចុះ សំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ដូចមានសំបុត្រអាពាហ៍ពិពាហ៍លេខ: ១៣ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៨ និងបានកូនស្រីមួយឈ្មោះ [redacted] សីគាវ៉ា ភេទស្រី កើតថ្ងៃទី ២៣ ខែសីហា ឆ្នាំ២០១១។



Scanned with CamScanner

នៅឆ្នាំ២០១៧ ដើមចោទ និងចុងចម្លើយមានទំនាស់គ្នា ទំនាស់រហូតបានបែកលំនៅតាំងពីថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៧ នោះរហូតដល់សព្វថ្ងៃនេះ។

**៣. ចំណុចវិវាទ និងចំណុចគ្មានវិវាទ**

**៣.១. ចំណុចវិវាទ**

**៤.ការអះអាងរបស់ភាគី៖**

**សេចក្តីថ្លែងការណ៍របស់ដើមចោទ៖**

ដើមចោទឈ្មោះ [redacted]សាមឿន ខ្លួនស្នើសុំដល់តុលាអោយចេញសាលក្រមដែលមានខ្លឹមសារ៖

-សុំលែងលះពីចុងចម្លើយឈ្មោះ [redacted] **ថាវី** ។

-សុំប្រគល់កូនស្រីឈ្មោះ [redacted] **ស៊ីតាវ៉ា** ទៅឱចុងចម្លើយជាអ្នកគ្រប់គ្រង។

-សុំផ្តល់ប្រាក់ឧបត្ថម្ភចិញ្ចឹមក្នុង១ខែចំនួន ២០ ម៉ឺនរៀល។

មូលហេតុនៃការសុំលែងលះដោយសាររស់នៅមិនចុះសំរុងនឹងគ្នាចុងចម្លើយជាប្រពន្ធតាមទៅរករឿងទៅដល់សាលារៀនធ្វើឲ្យខ្លួនខ្មាស់គេក៏សម្រេចចិត្តដាក់ពាក្យបណ្តឹងសុំលែងលះទៅ។ ខ្លួន និងចម្លើយបានរៀបការនៅឆ្នាំ២០០៨ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ដូចមានសំបុត្រអាពាហ៍ពិពាហ៍លេខ៖១៣ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៨ និងបានកូន១នាក់ឈ្មោះ [redacted] **ស៊ីតាវ៉ា** ភេទស្រី កើតថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១១។ ចំពោះទ្រព្យសម្បត្តិរួមខ្លួនសុខចិត្តប្រគល់ឲ្យចុងចម្លើយគ្រប់គ្រងទាំងអស់។ ខ្លួនបានបែកពីចេញចុងចម្លើយនៅឆ្នាំ២០១៧ រហូតមកដល់សព្វថ្ងៃនេះ ហើយក៏ពុំទាន់មានប្រពន្ធដែរ។ ខ្លួនមានមុខរបរជាគ្រូបង្រៀនប្រាក់ខែ ត្រឹមតែ១.២០០.០០០ រៀល មិនមានលទ្ធភាពជួយឧបត្ថម្ភដល់ចំនួន ២០០$ តាមការទាមទាររបស់ចុងចម្លើយបានទេ ដោយសព្វថ្ងៃខ្លួនត្រូវចំណាយជួលផ្ទះស្នាក់នៅផង និងចំណាយប្រចាំថ្ងៃផង ដោយខ្លួនសុខចិត្តជួយឧបត្ថម្ភក្នុង១ខែ ៧០$ ចុះ។

**សេចក្តីថ្លែងការណ៍របស់ចុងចម្លើយ៖**

ចុងចម្លើយឈ្មោះ [redacted] **ថាវី** ៖ ខ្លួនមិនឯកភាពលែងលះទេ មូលហេតុដោយសារដើមចោទខ្លួនឯងមានស្រីចុះចេញខ្លួនឯងគ្មានអ្នកណាដេញទេខ្លួនមានភស្តុតាងថាប់បានសំឡេងនិយាយតាមទូរស័ព្ទ ។ចំនែកឪពុកម្តាយបងប្អូនខ្លួនពុំមានជាប់ពាក់ព័ន្ធឡើយ។ ខ្លួនបានរៀបការជាមួយដើមចោទនៅឆ្នាំ២០០៨ និង បានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ដូចដើមចោទថាមែន និងបានកូនស្រីមួយឈ្មោះ [redacted] ស៊ីតាវ៉ា ភេទស្រី កើតថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១១ ប្រាកដមែន។ ចំពោះដើមចោទនៅតែប្តឹងសុំលែងលះខ្លួនសុំទាមទារសំណងចំនួន៥ម៉ឺនដុល្លាអាមេរិក តែពេលនេះខ្លួនសុំទាមទារអាហារកិច្ចចញ្ចឹមកូនក្នុង១ខែ ២០០$(ពីរយ)ដុល្លាអាមេរិក។

**<u>សំអាងហេតុ</u>**

**តាមលទ្ធផលនៃការសាកសួរដើមចោទ**

**និងពិនិត្យភស្តុតាងនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឃើញថា៖**



Scanned with CamScanner

១.សេចក្តីថ្លែងការណ៍របស់ដើមចោទឈ្មោះ [redacted] សាមឿន ខ្លួនស្នើសុំដល់តុលាការអោយចេញសាលក្រមដែលមានខ្លឹមសារ៖

-សុំលែងលះពីចុងចម្លើយឈ្មោះ [redacted] ថារី ។

-សុំប្រគល់កូនស្រីឈ្មោះ [redacted] សីតាភី ទៅចិចុងចម្លើយជាអ្នកគ្រប់គ្រង។

-សុំផ្តល់ប្រាក់ឧបត្ថម្ភចិញ្ចឹមក្នុង១ខែចំនួន ២០ ម៉ឺនរៀល។

មូលហេតុនៃការសុំលែងលះដោយសាររស់នៅមិនចុះសំរុង និងគ្នាចុងចម្លើយជាប្រពន្ធចេះតែតាមទៅរករឿងខ្លួនដល់សាលារៀនធ្វើឲ្យខ្លួនខ្មាស់គេក៏សម្រេចចិត្តដាក់ពាក្យបណ្តឹងសុំលែងលះទៅ។ ខ្លួន និងចម្លើយបានរៀបការនៅឆ្នាំ២០០៨ និងបានចុះសំបុត្រអាពាហ៍ត្រឹមត្រូវតាមច្បាប់ដូចមានសំបុត្រអាពាហ៍ពិពាហ៍លេខ៖១៣ ចុះថ្ងៃទី ២៥ ខែសីហា ឆ្នាំ២០០៨ និងបានកូន១នាក់ឈ្មោះ [redacted] សីតាភីភេទស្រីកើតថ្ងៃទី ២៣ ខែសីហា ឆ្នាំ២០១១។ ចំពោះទ្រព្យសម្បត្តិរួមខ្លួនសុខចិត្តប្រគល់ឲ្យចុងចម្លើយគ្រប់គ្រងទាំងអស់។ ខ្លួនបានបែកចេញពីចុងចម្លើយនៅថ្ងៃទី ១១-១២-២០១៧ រហូតមកដល់សព្វថ្ងៃនេះ ហើយក៏ពុំទាន់មានប្រពន្ធដែរ។ ខ្លួនមានមុខរបរជាគ្រូបង្រៀន មានប្រាក់ខែត្រឹមតែចំនួន ១.២០០.០០០រៀល មិនអាចជួយឧបត្ថម្ភដល់ ២០០$ បានទេ ព្រោះសព្វថ្ងៃចំណាយថ្លៃជួលផ្ទះផង ចំណាយប្រចាំថ្ងៃ ផង ពុំមាននៅសល់ទេ។

២/-សេចក្តីថ្លែងការណ៍របស់ចុងចម្លើយឈ្មោះ [redacted] ថារី ៖ ខ្លួនមិនឯកភាពលែងលះទេ មូលហេតុដោយសារដើមចោទខ្លួនឯងមានស្រីចុះចេញខ្លួនឯងគ្មានអ្នកណាដេញទេ ខ្លួនមានភស្តុតាងចាប់បានសំឡេងនិយាយតាមទូរស័ព្ទ។ ចំណែកឪពុកម្តាយបងប្អូនខ្លួនពុំមានជាប់ពាក់ព័ន្ធឡើយ។ ខ្លួនបានរៀបការជាមួយដើមចោទនៅឆ្នាំ២០០៨ និង បានចុះសំបុត្រអាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ដូចដើមចោទថាមែន និងបានកូនស្រីមួយឈ្មោះ [redacted] សីតាភីភេទស្រីកើតថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១១ ប្រាកដមែន។ ដើមចោទនៅតែប្តឹងសុំលែងលះខ្លួនសុំទាមទារសំណងចំនួន៥ ម៉ឺនដុល្លារអាមេរិក តែពេលនេះខ្លួនសុំទាមទារអាហារកិច្ចចិញ្ចឹមកូនក្នុង១ខែ ២០០$។

៣/-តាមសំបុត្រអាពាហ៍ពិពាហ៍លេខ៖ ១៣ ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ២០០៨ បញ្ជាក់ថាអ្នកទាំងពីរពិតជាប្តីប្រពន្ធនឹងគ្នាមែន។

៤/-តាមសំបុត្រកំណើតលេខ៖២៨ ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] សីតាភី កើតថ្ងៃទី២៣ ខែ សីហា ឆ្នាំ២០១១ ពិតជាមានឪពុកឈ្មោះ [redacted] សាមឿន និងម្តាយឈ្មោះ [redacted] ថារី ប្រាកដមែន។

៥/-ដើមចោទសុំប្រគល់កូនទៅឲ្យចុងចម្លើយគ្រប់គ្រងជាអ្នកមានអំណាចមេបា ចុងចម្លើយឯកភាព គប្បីតុលាការសម្រេចឲ្យចុងចម្លើយគ្រប់គ្រង តាមការព្រមព្រៀង។

៦/-ចុងចម្លើយស្នើសុំអាហារកិច្ចចិញ្ចឹមកូនក្នុង ១ខែ ២០០$ គប្បីតុលាការពិនិត្យ និងសម្រេចទៅតាមលទ្ធភាពជាក់ស្តែង។

៧/-ប្រាក់ប្រដាប់ក្តីត្រូវអនុវត្តតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។

**<u>សេចក្តីសេចក្តីសម្រេច</u>**

១/- ឲ្យឈ្មោះ [redacted] សាមឿន និងឈ្មោះ [redacted] ថារី លែងលះពីគ្នា។



Scanned with CamScanner

២/-កូនស្រីឈ្មោះ [redacted] សីតាភាំ ភេទស្រី អាយុ ៨ ឆ្នាំ ត្រូវប្រគល់ទៅឱ្យឈ្មោះ [redacted] ដារី ចុងចម្លើយ ជាគ្រប់គ្រង ចិញ្ចឹមបីបាច់ថែរក្សាតាមការព្រមព្រៀងរបស់គូរភាគី ដោយតម្រូវឱ្យដើមចោទឈ្មោះ [redacted] សាមឿន ផ្តល់អាហារកិច្ចចិញ្ចឹមកូនក្នុង១ខែ ចំនួន ៧០$ រហូតដល់កូនពេញនីតិភាព។ សំណើលើសពីនេះច្រានចោល។

៣/-ទុកសិទ្ធិឱ្យឈ្មោះ [redacted] សាមឿន ទៅសួរសុខទុក្ខកូនបាន។

-មាតាបិតាត្រូវបំពេញសិទ្ធិ និងកាតព្វកិច្ចឱ្យសមស្របតាមមាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី។

៤/-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

៥-សាលក្រមនេះបានទាញហេតុផលដោយផ្ទាល់មាត់និងប្រកាសជាសាធារណៈនៅថ្ងៃទី ២០ ខែ សីហា ឆ្នាំ២០១៩ ចំពោះមុខដើមចោទ និងចុងចម្លើយ។

-ទុកសិទ្ធិប្តឹងតវ៉ាតាមកំណត់ច្បាប់។

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ អង្គារ០៥រោច ខែ ស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

កណ្តាល,ថ្ងៃទី ២០ ខែ សីហា ឆ្នាំ២០១៩

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រម**

[redacted]